Khmer | ភាសាខ្មែរ



# សាលាមត្តេយ្យ ចាប់ផ្តើម មុនពេលកំណត់ សម្រាប់ជនភៀសខ្លួន និងអ្នកស្វែងរក សិទ្ធិជ្រកកោន

VICTORIA State Government | Department of Education

The Education State

## ហេតុអ្វីបានជាសាលាមត្តេយ្យមានសារៈសំខាន់?

សាលាមត្តេយ្យជួយរៀបចំកុមារឱ្យទទួលបានជោគជ័យនៅសាលារៀន និងក្នុងជីវិត។ នៅសាលាមត្តេយ្យ កុមារប្រើប្រាស់ការលេងដើម្បីរៀនអំពីភាសា លេខ និងលំនាំនានា។ ពួកគេក៏រៀនពីរបៀបចុះសម្រុងជាមួយអ្នកដទៃ ចែករំលែក ស្ដាប់ និងគ្រប់គ្រងអារម្មណ៍របស់ពួកគេផងដែរ។ គ្រូបង្រៀនជួយកុមារឱ្យមានការចង់ដឹងចង់ឃើញ ច្នៃប្រឌិត និងមានទំនុកចិត្តលើការរៀនសូត្រ។ ការស្រាវជ្រាវបង្ហាញថា ការរៀន 2 ឆ្នាំនៅសាលាមត្តេយ្យ គឺល្អប្រសើរជាងការរៀនមួយឆ្នាំនៅសាលាមត្តេយ្យ។

## តើសាលាមត្តេយ្យចាប់ផ្ដើមមុនពេលកំណត់ (Early Start Kindergarten) ជាអ្វី?

សាលាមត្តេយ្យចាប់ផ្ដើមមុនពេលកំណត់ ផ្ដល់ឱ្យកុមារដែលមានអាយុ 3 ឆ្នាំមកពីសាវតារជនភៀសខ្លួន ឬអ្នកស្វែងរកសិទ្ធិជ្រកកោននូវពេលរៀនសូត្រចំនួន 15 ម៉ោងក្នុងមួយសប្ដាហ៍នៃថ្នាក់មត្តេយ្យដោយឥតគិតថ្លៃ ឬតម្លៃទាប។

ការដាក់ពាក្យសុំចូលរៀនសាលាមត្តេយ្យចាប់ផ្ដើមមុនពេលកំណត់ ត្រូវបានធ្វើឡើងដោយសាលាមត្តេយ្យ។ ប្រាក់ឧបត្ថម្ភការចាប់ផ្ដើមសាលាមត្តេយ្យមុនពេលកំណត់ ត្រូវបានបង់ដោយផ្ទាល់ទៅឱ្យសាលាមត្តេយ្យ។

## តើកូនរបស់ខ្ញុំមានសិទ្ធិទទួលទេ?

ដើម្បីមានសិទ្ធិទទួល កូនរបស់អ្នកត្រូវតែមានអាយុ 3 ឆ្នាំនៅត្រឹមថ្ងៃទី 30 ខែមេសា នៅក្នុងឆ្នាំដែលពួកគេចាប់ផ្ដើមនៅសាលាមត្តេយ្យ ហើយអ្នក ឬកូនរបស់អ្នក៖

- → មានទិដ្ឋាការជនភៀសខ្លួន ឬទិដ្ឋាការមនុស្សធម៌ ឬ
- → កំពុងដាក់ពាក្យសុំទិដ្ឋាការជនភៀសខ្លួន ឬទិដ្ឋាការមនុស្សធម៌ ឬ
- → ធ្លាប់កាន់ទិដ្ឋាការជនភៀសខ្លួន ឬទិដ្ឋាការមនុស្សធម៌ពីមុន ឬ
- → មាន ImmiCard បច្ចុប្បន្ន ឬផុតកំណត់។

ប្រសិនបើគ្មានអ្វីអនុវត្តនឹងចំណុចទាំងនេះទេ ប៉ុន្តែអ្នក ឬកូនរបស់អ្នកធ្លាប់ជាជនភៀសខ្លួន ឬអ្នកស្វែងរកសិទ្ធិជ្រកកោន ឬធ្លាប់មានបទពិសោធន៍ស្រដៀងគ្នា នោះកូនរបស់អ្នកអាចនៅតែមានសិទ្ធិទទួល។

សូមទាក់ទងការិយាល័យក្រសួងអប់រំក្នុងតំបន់របស់អ្នក ដើម្បីសួរអំពីការលើកលែង។ អ្នកក៏អាចស្នើសុំឱ្យអ្នកជំនាញណាម្នាក់ដែលគាំទ្រអ្នក ទាក់ទងក្រសួងជំនួសអ្នកបានដែរ។

## តើថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep) ជាអ្វី?

សាលាមត្តេយ្យសម្រាប់កុមារអាយុបួនឆ្នាំកំពុងផ្លាស់ប្ដូរទៅ ថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep) នៅក្នុងរដ្ឋវិចថូរៀ។ នេះមានន័យថាកុមារនឹងមានសិទ្ធិទទួលបានចំនួនម៉ោងបន្ថែមដើម្បីរៀនសូត្រ និងទំនាក់ទំនងសង្គមតាមរយៈការលេងនៅក្នុងឆ្នាំសិក្សាមុនពេលចាប់ផ្ដើមចូលរៀននៅសាលា។ ថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep) នឹងត្រូវបានផ្ដល់ជូនតាមរយៈសាលាមត្តេយ្យឯករាជ្យ (តាមវគ្គ) និងមជ្ឈមណ្ឌលថែទាំកុមារពេលថ្ងៃរយៈពេលយូរ។

ជាផ្នែកនៃ ថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep), ចំនួនម៉ោងនៅសាលាមត្តេយ្យឥតគិតថ្លៃ កំពុងកើនឡើងសម្រាប់កុមារមកពីសាវតារជនភៀសខ្លួន ឬអ្នកស្វែងរកសិទ្ធិជ្រកកោន មិនថាអ្នករស់នៅទីណាក្នុងរដ្ឋវិចថូរៀនោះទេ។

អ្នកអាចសួរសេវាកម្មសាលាមត្តេយ្យរបស់អ្នកអំពី ថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep) រួមទាំងចំនួនម៉ោងដែលពួកគេផ្តល់ជូន និងថ្ងៃដែលកូនរបស់អ្នកអាចចូលរៀន។

ប្រសិនបើកូនរបស់អ្នកបានចុះឈ្មោះនៅ សាលាមត្តេយ្យចាប់ផ្តើមមុនពេលកំណត់រួចហើយ ពួកគេក៏មានសិទ្ធិទទួលបានថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep) ដែរ។

ដើម្បីស្វែងយល់បន្ថែមអំពី ថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep) រួមទាំងធនធាន និងការបកប្រែ សូមចូលមើល៖ **vic.gov.au/pre-prep**

## តើខ្ញុំចុះឈ្មោះកូនរបស់ខ្ញុំដោយរបៀបណា?

អ្នកអាចចុះឈ្មោះកូនរបស់អ្នកដោយទាក់ទងសេវាកម្មសាលាមត្តេយ្យដែលនៅជិតអ្នក ឬសាលាសង្កាត់ក្នុងតំបន់របស់អ្នក ហើយស្នើសុំចូលរៀនសាលាមត្តេយ្យចាប់ផ្តើមមុនពេលកំណត់ និងចូលរៀនថ្នាក់មុន-ចូលសាលាត្រៀម (Pre-Prep)។

ប្រាប់សាលាមត្តេយ្យប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ពីព្រោះពួកគេអាចប្រើប្រាស់សេវាកម្មបកប្រែផ្ទាល់មាត់តាមទូរសព្ទដោយឥតគិតថ្លៃ។

ប្រសិនបើអ្នកត្រូវការជំនួយដើម្បីចុះឈ្មោះ សូមសួរក្រសួងអប់រំ ឬអ្នកជំនាញណាម្នាក់ដែលគាំទ្រអ្នក ដូចជា៖

- បុគ្គលិកគាំទ្រ
- បុគ្គលិកដែលមានការយល់ដឹងពីវប្បធម៌
- គិលានុបដ្ឋាកសុខភាពមាតា និងកុមារ
- អ្នកសម្របសម្រួលក្រុមកុមារតូចៗលេងជាមួយគ្នាដែលមានការគាំទ្រ
- បុគ្គលិកផ្សព្វផ្សាយភាពចម្រុះទៅដោយវប្បធម៌ និងភាសាផ្សេងៗគ្នា (CALD)។

## តើកូនរបស់ខ្ញុំគួរទៅ ថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep)/សាលាមត្តេយ្យសម្រាប់កុមារអាយុបួនឆ្នាំដែរឬទេ?

បាទ/ចាស។ បន្ទាប់ពីសាលាមត្តេយ្យចាប់ផ្តើមមុនពេលកំណត់ កូនរបស់អ្នកមានសិទ្ធិទទួលបាន ថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep) ដោយឥតគិតថ្លៃ ឬតម្លៃទាប។ នេះនឹងជួយពួកគេឱ្យបន្តអភិវឌ្ឍចំណុចខ្លាំងរបស់ពួកគេ និងរៀបចំពួកគេសម្រាប់ចូលរៀននៅសាលា។ កុមារដែលមានសិទ្ធិទទួលបាន ឬបានចូលរៀននៅសាលាមត្តេយ្យចាប់ផ្តើមមុនពេលកំណត់ ក៏មានសិទ្ធិទទួលបានថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep) ដោយឥតគិតថ្លៃ ឬតម្លៃទាបសម្រាប់រយៈពេលជាង 15 ម៉ោងក្នុងមួយសប្តាហ៍ដែរ។

អ្នកអាចសួរសេវាកម្មរបស់អ្នកអំពី ថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep) រួមទាំងចំនួនម៉ោងដែលពួកគេផ្តល់ជូន និងថ្ងៃដែលកូនរបស់អ្នកអាចចូលរៀនបាន។

ព្យាយាមចុះឈ្មោះកូនរបស់អ្នកចូលរៀន ថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep) ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីធានាថាកូនរបស់អ្នកទទួលបានកន្លែងមួយ ពីព្រោះគ្មានការធានាកន្លែងរៀននៅសាលាមត្តេយ្យដែលអ្នកពេញចិត្តនោះទេ។

ស្វែងយល់បន្ថែមអំពី ថ្នាក់មុនចូល-សាលាត្រៀម (Pre-Prep) នៅ៖ **vic.gov.au/pre-prep**

# តើខ្ញុំអាចរកព័ត៌មានបន្ថែមអំពី សាលាមត្តេយ្យចាប់ផ្តើមមុនពេលកំណត់នៅឯណា?

- ចូលមើល **vic.gov.au/education** ហើយស្វែងរក **សាលាមត្តេយ្យចាប់ផ្តើមមុនពេលកំណត់** ឬ
- ទូរសព្ទទៅការិយាល័យក្រសួងអប់រំក្នុងតំបន់របស់អ្នក។

## ទំនាក់ទំនងការិយាល័យតាមតំបន់

| តំបន់ | ទីកន្លែង |
|---|---|
| ភាគឦសាននៃរដ្ឋវិចថូរៀ<br>**(North-Eastern Victoria)**<br>**1300 333 231** | Benalla<br>Glen Waverley<br>Ringwood<br>Seymour<br>Shepparton<br>Wodonga |
| ភាគពាយ័ព្យនៃរដ្ឋវិចថូរៀ<br>**(North-Western Victoria)**<br>**1300 338 691** | Bendigo<br>Coburg<br>Greensborough<br>Mildura<br>Swan Hill |
| ភាគអាគ្នេយ៍នៃរដ្ឋវិចថូរៀ<br>**(South-Eastern Victoria)**<br>**1300 338 738** | Bentleigh East<br>Dandenong<br>Frankston<br>Leongatha<br>Moe<br>Sale<br>Warragul |
| ភាគនិរតីនៃវិចថូរៀ<br>**(South-Western Victoria)**<br>**1300 333 232** | Ballarat<br>Footscray<br>Geelong<br>Horsham<br>Keilor<br>Warrnambool |

ដើម្បីទទួលបានជំនួយជាភាសារបស់អ្នក៖

- ហៅទូរសព្ទទៅសេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ថ្នាក់ជាតិតាមលេខ **131 450**
- ស្នើសុំឱ្យអ្នកបកប្រែផ្ទាល់មាត់ហៅទូរសព្ទទៅលេខតំបន់របស់អ្នក (សូមមើលខាងលើ)
- អ្នកបកប្រែផ្ទាល់មាត់នឹងនៅជាប់តាមទូរសព្ទ ហើយបកប្រែ។

បានបោះពុម្ពផ្សាយដោយក្រសួងអប់រំ ទីក្រុងមែលប៊ន ខែវិច្ឆិកា ឆ្នាំ 2025 (បានកែសម្រួល) © រដ្ឋវិចថូរៀ

VICTORIA State Government
Department of Education
The Education State